## ភាគទី ១៦

# ទោណាចិត្តផុតរលត់សង្គ្រាម

ការសង្គ្រាមក្នុងគ្រានេះ ជិតនឹងដល់នូវទីបំផុតហើយ ព្រោះទោណាជាស្ដេចសឹកធំ និងកណ៌ ទាហានសំខាន់ដល់នូវមរណៈ ។ ក្នុងវារៈនេះ ការសង្គ្រាមគេធ្វើយ៉ាងសាហាវបំផុត ផលដែលកើតពីការសាហាវនេះ គឺក្បាលទាហានត្រូវអាវុធដាច់ធ្លាក់អំពីស្មាទៅរមៀលដោយដី សពទាហានដែលត្រូវអាវុធមានស្នាមកញ្ឆែត កញ្ឆតដេកកើយគងលើគ្នាត្រៀបត្រា, ខ្មោចសត្វពាហនៈ ដែលត្រូវនឹងធ្នូ ឬលំពែងពួយ ត្រូវនឹងបររថកិន ក៏ហើមប៉ោងចង្រ្គឹងចង្រ្គាងពាសពេញស្នាមយុទ្ធ, សម្លេងទ្រហោយំ, សម្លេងថ្ងូរមុខគួរឲ្យសង្វេគវេទនា, សម្លេងអ៊ឹងអ៊ាស់កោលាហល, សម្លេងនិយាយព្យាបាទគុំគួន និងសម្លេងសើចក្អាកក្អាយដោយមានជ័យ ។

ថ្ងៃព្រឹកឡើង តអំពីមរណភាពនៃរាជាទ្រុបទមក, ធ្រស្តទ្យុម័ន ឱរសរបស់ព្រះអង្គ ចេញទៅស្វែងរកខ្លួនអ្នកសម្លាប់ព្រះបិតាតាំងចិត្តថានឹងសម្លាប់ឲ្យស្លាប់ទៅតាមគ្នាទាល់តែបាន បើមិនបានសម្រេចដូចបំណងទេ ក៏ស៊ូផ្ដាច់បង់ជីវិតរបស់ខ្លួនក្នុងការព្យាយាមនោះ លុះភីមឃើញធ្រស្តទ្យុម័ន កំលោះតូចប្រុងនឹងចេញទៅច្បាំងដោយបំណងយ៉ាងនោះហើយ ក៏ចាប់ដៃខ្ទាប់និយាយថា «ទ្រង់នៅក្មេង



ណាស់ ដែលទ្រង់នឹងទៅធ្វើការសងសឹកដល់ទោណា អ្នកក្លៀវក្លាដើម្បីកែកំហឹងពីរឿងមរណភាពនៃព្រះរាជបិតានោះ ឃើញជាពុំល្មមធួននឹងការទេ, ឯទាហានចាស់នោះជាអាហារដ៏រឹងស្វិតណាស់ មិនជាគួគ្នានឹងធ្មេញដ៏ទន់ ៗ របស់ទ្រង់ ដែលប្រុងនឹងទំពាឲ្យល្អិតល្អោចបានឡើយ ទុកឲ្យខ្ញុំវិញចុះ ខ្ញុំទៅច្បាំងជំនួសទ្រង់ ខ្ញុំនឹងទៅសងសឹកពីរឿងមរណភាពនៃព្រះរាជបិតារបស់ទ្រង់ឲ្យបាន» ថាហើយក៏ច្រានក្សត្រិយ៍កំលោះនោះឲ្យថយក្រោយក្រាកចេញទៅ ភីមលោតចូលទៅរកទោណា អ្នកចម្បាំងពីរប្រាណ បានចូលប្រយុទ្ធគ្នាយ៉ាងល្អមើល គ្មានអ្នកណាចាញ់ប្រៀបអ្នកណាឡើយ ល្មមតដៃវាយវាត់គ្នាបាន ទាំងពីរប្រាណឥតថយក្រោយមួយជំហានសោះ ។ ចំណែកភីមសូម្បីមានកម្លាំងខ្លាំងដល់ម្ល៉េះក្ដី ក៏នៅតែមិនទាន់ធួនល្មមជាគូគួរតដៃនឹងសេចក្ដីស្ទាញស្ទាត់ប៉ិនប្រសប់របស់ព្រាហ្មណាចារ្យដែរ ។

ក្រឹស្ណៈឃើញឥតប្រយោជន៍ក្នុងការច្បាំង ដោយអាងតែកម្លាំងសំពងគ្នាម្យ៉ាងប៉ុណ្ណោះ ទើបទ្រង់ទូលពន្យល់ណែនាំយុធិស្ឋិរឲ្យប្រើវិធីកលយុទ្ធជាជំនួសកម្លាំងទាហានទៅវិញ ។ យុធិស្ឋិរ មុនដំបូងទ្រង់មិនពេញព្រះហឫទ័យក្នុងការប្រើវិធីឧបាយកល ដោយទ្រង់យល់ថាជាឧបាយកលកោងកាចអាក្រក់ ព្រោះហឫទ័យរបស់ទ្រង់ប្រកបដោយមេត្តាករុណាជាច្រើន ទើបទ្រង់មិនព្រមប្រើវិធីកលយុទ្ធជាវិធីដែលចរិយាទាហានជាន់ខ្ពស់បានអនុញ្ញាតឲ្យប្រើហើយ ។ ប៉ុន្តែ

ទីប្រឹក្សារបស់ទ្រង់ទូលពន្យល់ថា «ត្រូវតែធ្វើការសងសឹកនឹងសត្រូវវិញដោយវិធីឧបាយកលយ៉ាងនេះទើបសមគ្នា ព្រោះសត្រូវរបស់យើង គេចេះតែអាស្រ័យទៅលើឧបាយកលវៀចកោងជាដរាប នឹងគេប្រព្រឹត្តអសត្រជាសរណៈរួចមកហើយ, បើទ្រង់មិនសព្វព្រះហឫទ័យក្នុងការគ្រាន់តែធ្វើសងសឹកសត្រូវវិញទេ ចុះទ្រង់នឹងខំច្បាំងធ្វើអ្វីទៀត, ម្ដេចក៏មិនលើកលែងច្បាំងគ្នាចេញ ហើយព្រមចុះចាញ់នៅក្នុងកណ្ដាប់ដៃនៃទុរយោធន៍ទៅ ? ទ្រង់ភ្លេចសំណាមចាស់ដែលគេធ្វើដល់ទ្រង់ហើយឬនៅ ? រឿងលេងស្កាបង្កប់ជាតុដ៏ធ្ងន់ខាងក្នុង, រឿងនិរទេស, រឿងប្រមាថមើលងាយទ្រៅបទី» ។ កាលបើប្រឹក្សាទូលរំឭកពីរឿងទាស់ទែងគ្នាក្នុងគ្រាមុននោះហើយ យុធិស្ឋិរក៏ភ្ញាក់ព្រើតក្នុងព្រះហឫទ័យ ទ្រង់រំពឹងគិតដល់រឿងឈឺចិត្តនោះ ព្រះនេត្រទ្រង់ឡើងរលីងរលោងដោយអស្សុជល, ព្រះភក្ត្រជ្រប់គង់ស្ងៀម អាការៈដែលទ្រង់ជ្រប់ហើយគង់នៅស្ងៀមនោះ បញ្ជាក់ឲ្យដឹងថា «ទ្រង់យល់ព្រមឲ្យប្រើវិធីកលយុទ្ធនោះហើយ» ។ ប៉ុន្តែពួកបាណ្ឌពទាំងនោះ តាំងចិត្តនឹងប្រើវិធីដែលប្រាសចាកទោសមន្ទិលសៅហ្មង ដើម្បីនឹងកម្រាបទោណ អ្នកក្លៀវក្លាខ្លាំងពូកែនោះចេញឲ្យបាន ។

គ្រានោះ ភីមបានពិឃាតទាហានបាស្តិនបុរបុរសម្នាក់ ដែលមានឈ្មោះថា «អស្វត្ថាម័ន» រួចប្រើឧបាយកលស្រែកបន្ត ៗ គ្នាទូទៅពេញស្នាមយុទ្ធថា «សឹកបានសម្លាប់អស្វត្ថាម័នស្លាប់ទៅហើយ»។



ពួកកុរុបានឮសម្រែកនោះហើយ ក៏ចូលចិត្តថា សឹកបានសម្លាប់អស្វត្ថាម័នបុត្រសម្លាញ់តែមួយរបស់ទោណ (ដែលមានឈ្មោះដូចគ្នានឹងដំរីសឹក) ។ ដោយហេតុស្ទូរសម្លេងលាន់ឮគឹកកងរំពងជ្រួលច្របល់ខ្លាំងពេក ពួកអ្នកចាំស្ដាប់សេចក្ដីរាយការណ៍ មិនអាចនឹងស្ដាប់ចាប់យកសេចក្ដីឲ្យច្បាស់លាស់បាន អ្នកស្ដាប់ត ៗ គ្នាមកចេះតែរាយសេចក្ដីផ្សេងៗស្មានយក ប៉ុន្តែស្មានមិនត្រូវ ត្រឡប់ជាចូលចិត្តជ្រុលហួសខុសទៅ ។ ក្សត្រិយ៍កុរុអង្គខ្លះចូលទៅរកទោណដើម្បីសម្ដែងសេចក្ដីទោមនស្សតូចចិត្តរួមផង ។ ដំណឹងនេះធ្វើឲ្យទោណធ្លាក់ថ្លើមក្ដុក ស្ទើរតែមិនចង់ជឿត្រចៀករបស់ខ្លួនទៀត ទោណក៏ចូលមកឯបន្ទាយបាណ្ឌពដោយដៃទទេ ឥតកាន់អាវុធសោះ ដើម្បីសាកសួរឲ្យបានដឹងសេចក្ដីពិតអំពីយុធិស្ឋិរ ដែលជាអ្នកធ្លាប់ពោលតែពាក្យពិតម្យ៉ាងថា «ចូរត្រាស់មកមើលយុធិស្ឋិរ ទ្រង់ជាអ្នកធ្លាប់ពោលតែពាក្យពិតតាំងកាលណា ៗ មកហើយ, អស្វត្ថាម័ន បុត្រដ៏ក្លាហានរបស់ខ្ញុំ ត្រូវអាវុធស្លាប់ក្នុងទីចម្បាំងមែនឬទេ ? យុធិស្ឋិរបានឮពាក្យបុច្ឆានេះ បណ្ដាលឲ្យទ្រង់ទាល់គំនិត មិនដឹងបើនឹងគិតអភិប្រាយប្រាប់ផ្លូវណា គឺប្រការមួយ ទ្រង់ត្រូវតែពោលពាក្យពិតគ្រប់ផ្លូវ, ប្រការពីរ ទ្រង់ត្រូវតែរក្សារដ្ឋប្រសាសនោបាយក្នុងផ្លូវរាជការ ត្រូវតែខំបិទបាំងសេចក្ដីពិតនេះទុកឲ្យជិត, ទ្រង់ត្រូវរកឧបាយគិតដើរអែបផ្លូវកណ្ដាលរវាងសេចក្ដីពិតនឹងសេចក្ដីកុហក ដើម្បីមិនឲ្យខូច

ការរាជការ ដោយហេតុអាស្រ័យជាផ្លូវបញ្ឈៀស មិនបាច់ឲ្យពោលចំពោះសេចក្ដីពិត ទើបទ្រង់ត្រាស់ថា «អស្វត្ថាស្លាប់ទៅហើយ, តែខ្ញុំពោលនេះសំដៅដល់ដំរីស្លុក» ពាក្យបន្ទាប់បន្សំខ្លី ៗ តប្រយោគក្រោយនេះ ទ្រង់ត្រាស់ដោយព្រះសូរសៀងយ៉ាងស្រាលជាបំផុតស្រាលដល់តែមិនដឹងខ្លួន ឬមិនឮដោយត្រចៀករបស់ខ្លួនទោណស្ដាប់យល់ច្បាស់តែត្រង់ពាក្យឃ្លាខាងដើម ឯឃ្លាខាងចុងស្ដាប់មិនទាន់ មិនដឹងជាថាអ្វី ព្រោះវេលានោះ ទោណកំពុងកង្វល់ខ្លាំង ។

ទោណាចារ្យ មិនបង្អែបង្អង់ជជែកតទៅទៀត ឲ្យយឹតយូរការប្រញាប់ប្រញាល់ត្រឡប់ទៅទីចម្បាំងរបស់ខ្លួនវិញ ចេះតែនឹកក្ដុក ៗ ក្នុងចិត្តរបស់ខ្លួន បាត់មាត់ បាត់ក ស្ញៀមឈឹង ចិត្តរបស់គាត់ថយខ្សោយកម្លាំងចុះ ឥន្ទ្រីយ៍ទាំងអស់លែងកម្រើក បង្អង់ចាំតែមរណនឹងមកដល់ប៉ុណ្ណោះ ។ ធ្រិស្ដទ្យុម័នបានប្រុងប្រៀបខ្លួនជានិច្ច ចាំគន់មើលឲ្យតែបានឱកាសពេលណា នឹងសងសឹកវិញពេលនោះ ព្រោះទ្រង់ចាំបានច្បាស់ថា «ទោណជាអ្នកសម្លាប់ព្រះរាជបិតារបស់ទ្រង់» ទោះបី ភីមមិនអនុញ្ញាត ឲ្យចេញតដៃដោយពេញមុខក្ដី ទ្រង់ក៏នៅតែខំខ្វល់ខ្វាយរកឱកាសនឹងសងសឹកមរណៈនៃព្រះរាជបិតាឲ្យបានវិញជានិច្ច ។ ពេលនេះជាឱកាសល្អរបស់គេហើយ ដ្បិតទោណទ្រមអន់កម្លាំងកាយចិត្ត ស្រពន់ស្រពោនណាស់ មិនក្លាហានដូចកាលមុនដែលកន្លងមក ហើយគ្រានេះគាត់គ្រាន់តែមានកិរិយាឫកពាជា



មនុស្សចាស់ព្រឹទ្ធាចារ្យសំណាំសំនួនប៉ុណ្ណោះ ហេតុនោះខ្លួនគាត់ពេលនេះ ក្លាយទៅជាវង់សម្រាប់ឲ្យធ្រិស្ដទ្យុម័នប្រហារបានដោយងាយៗ។ អំពីនោះមួយស្របក់មក ទោណក៏ត្រូវកូនសរដែលធ្រិស្ដទ្យុម័នថ្លែងទៅអំពីចម្ងាយ ក្ស័យជីវិតនៅកណ្ដាលស្នាមយុទ្ធមួយរំពេច ។

វេលានោះកងទ័ពកុរុនៅទំនេរគ្មានអ្នកណានាំទ័ពតទៅទៀត។ ភីស្មៈផ្ទំលើធ្នូបិដ្ឋ រង់ចាំមរណៈកាលនឹងមកដល់ ។ ឯទោណក៏ដួលដេកដាច់ខ្យល់ស្លាប់ក្នុងថ្ងៃនេះទៅហើយ ខ្វះអ្នកធំនឹងទទួលតំណែងជាចមពលតទៅទៀត ហេតុនោះ ទុរយោធន៍ទើបស្ដេចប្រញាប់ចូលទៅរកកណ៌ អ្នកសំណព្វគាប់ចិត្តមកពីដើម ទ្រង់ត្រាស់ថា «នែកណ៌ ! វេលានេះ មានតែអ្នកម្នាក់ឯងប៉ុណ្ណឹង ដែលអាចនឹងយឹតយោងជ្រោងស្វយកុរុឲ្យគង់វង្សនៅបាន ដោយថ្វីដៃដ៏ល្បីរបស់អ្នក, ភីស្មៈជាអ្នកចម្បាំងឯកឥតអ្នកណាប្រៀបផ្ទឹមបានជាប្រាកដ ប៉ុន្តែមកពីគេមានសេចក្ដីលំអៀងធ្ងន់ទៅខាងពួកបាណ្ឌពនោះ បានធ្វើឲ្យដៃរបស់គេទន់ខ្សោយក្នុងការតស៊ូ, ឯទោណសោត ក៏ជាអ្នកខ្លាំងពូកែយ៉ាងឆើតឥតអ្នកណាប្រៀបស្មើដែរ ប៉ុន្តែសេចក្ដីស្រឡាញ់ពួកបាណ្ឌពជាកូនសិស្សសឹងត្រាំស្អិត នៅក្នុងសន្តានចិត្តយូរមកហើយនោះ វាមកធ្វើឲ្យសេចក្ដីក្លាហានរបស់គេថយខ្សោយចុះទៅ, កណ៌ ! ចំណែកអ្នកឯងគ្មានខ្វះកន្លះត្រង់ណាក្នុងរឿងនេះទេ, ចូរអ្នកនាំទ័ពរបស់យើងចូល

វាយសត្រូវឲ្យខ្ទេចខ្ទីអស់ទៅ នាមរបស់អ្នកនឹងលេចឮល្បីល្បាញតទៅរហូតដល់កូនចៅនៅខាងក្រោយ ថាខ្លួនអ្នកជាទាហានកុរុដ៏ក្លាហានបំផុត»។

កណ៌ឆ្លើយដោយសុភាពថា «ទូលបង្គំនឹងទទួលធ្វើការតាមមុខងាររបស់ទូលបង្គំ ដោយសត្យសុចរិតចំពោះព្រះមហាក្សត្រ និងស្រុកទេសរបស់ទូលបង្គំ»។

កណ៌ មានភក្ត្រដ៏ប៉ប្រិមក្នុងតំណែងកិត្តិយស ដែលទទួលថ្មី បររថសឹកគគ្រឹកចូលទៅពុះពារកណ្ដាលចំណោមកងទ័ពបាណ្ឌពដោយរួសរាន់ ។ មរណភ័យ និងសេចក្ដីស្រេវស្រើព្រួច បានចូលគ្របសង្កត់ហាទយវត្ថុរបស់មនុស្សទូទាំងស្នាមយុទ្ធ ។ ឯសេចក្ដីបំណងដ៏ធំរបស់កណ៌នោះ គេប៉ុនប៉ងតែនឹងចាប់បេះដូងនៃអរជុនដោយកូនសរតែប៉ុណ្ណោះ ។ ចំណែកសេចក្ដីប្រាថ្នារបស់អរជុនវិញ គេចង់តែស៊ីសាច់ប្របាច់ឈាមកណ៌ឲ្យបាន ។ វេលានោះ អរជុន កំពុងតែជាប់ដៃប្រយុទ្ធនឹងកងសឹកដទៃនៅភាគម្ខាងនៃស្នាមយុទ្ធ ។ កណ៌ខំបររថសឹកស្វះស្វែងរកអរជុនជាយូរ មិនជួបប្រទះប៉ះគ្នាសោះ ។ ប៉ុន្តែឯការផ្លាស់ប្ដូរឲ្យកណ៌ ឡើងយសស័ក្តិជាមេទ័ពកុរុនោះ ជាការត្រូវចិត្តអរជុនយ៉ាងបំផុត ។ អ្នកធំជាអ្នកនាំទ័ពកុរុដែលល្បីនាម នាំគ្នាផុតរលត់សង្ខារទៅតាម ៗ គ្នា ។ អ្នកខ្លាំងពូកែដែលល្មមនឹងបញ្ជាការកងទាហានកុរុបាន នៅសល់តិចរូបណាស់ទៅហើយ ព្រោះហេតុនោះ



បើប្រសិនជាពួកបាណ្ឌព គ្រញេចកណ៌ម្នាក់បានទៀតហើយ ស្បើយទ្រូងយ៉ាងធំ ការប្រយុទ្ធតទៅទៀតនៃកុរុ មុខជាគ្មានអ្នកណានឹងអាចធ្វើបាន ឬម្យ៉ាងទៀត ល្មមនឹងឲ្យឈ្នះបានថា «មិនជាការសំខាន់ប៉ុន្មានទេ»។

វេលាតមកមិនជាយូរប៉ុន្មាន អ្នកចម្បាំងឯកទាំងពីរប្រាណ ក៏បានជួបប្រទះប៉ះគ្នាគ្រាំ ដូចខ្យល់កំបុតត្បូង ។ ការតស៊ូនៃអ្នកទាំងពីរដែលមានបំណងដូចគ្នាមកយូរហើយ ស្រាប់តែបានឱកាសមកជួបប្រទះគ្នាគ្រានេះ គេបានចូលតយុទ្ធសម្ដែងមហិទ្ធិឫទ្ធិស្នាដៃ មុខគួរឲ្យស្ញប់ស្ញែងពេកណាស់, តាំងពីព្រឹកដល់ថ្ងៃត្រង់, តាំងពីថ្ងៃត្រង់ដល់ព្រលប់សន្សើមធ្លាក់ អ្នកទាំងពីរកើតទោសោ ប្រឡូកគ្នាតាមរបៀបយុទ្ធវិធីខ្លួននិងខ្លួន, ដាវនិងដាវ, ធ្នូនិងធ្នូ រាល់ ៗ ភ្លេងជាលំដាប់ទៅ ធ្វើឲ្យគេកើតទោសោ កាន់តែខ្លាំងឡើង ៗ ជាពន្លឹក ទាល់តែអស់ពេលទិវា ត្រែខ្លីក៏ផ្លុំជាអាណត្តិសញ្ញាសម្រាប់ច្បាំងគ្នាក្នុងថ្ងៃនេះ ។ ការច្បាំងនៅមិនទាន់ឈ្នះចាញ់ដាច់ខាតទេ ។

វេលាយប់នោះ ទុរយោធន៍ត្រាស់ហៅប្រជុំគ្នាដើម្បីប្រឹក្សារាជការសង្គ្រាម ។ ក្នុងការប្រជុំនោះ ទ្រង់ត្រាស់ថា «ពេញ ១៦ ថ្ងៃមកហើយ យើងបានដកដង្ហើមធំឥតដាច់ ទាំងសាច់សាលោហិតរបស់យើងស្លាប់ចោលទៅទទេ ៗ ការសង្គ្រាមនៅតែច្បាំងគ្នាគគ្រឹកដោយភ្លើងកំណាចឥតស្ងប់ស្ងាត់សោះ ទាហានដ៏ក្លាហានរបស់យើងរាប់

រយនាំគ្នាស្លាប់បាត់អស់ទៅ ឯជ័យជម្នះក៏នៅតែមើលមិនឃើញស្រមោលសោះ»។

សេចក្ដីតូចព្រះទ័យដូចជាន់មុនបានកើតឡើងដល់ទុរយោធន៍ម្ដងទៀត តាំងពីចាប់ធ្វើសង្គ្រាមជាច្រើនថ្ងៃមកហើយ ទ្រង់ឥតរីករាយសប្បាយព្រះទ័យដល់បន្តិចសោះ សូម្បីនៅគ្រាដែលទ្រង់មានជ័យជម្នះ បានប្រៀបក្នុងជើងចម្បាំហើយ ក៏ទ្រង់នៅតែគ្មានផ្លូវសប្បាយព្រះទ័យដែរ ទ្រង់នឹកអស់សង្ឃឹមជានិច្ចក្នុងរឿងមានជ័យដូចកាលមានពេលខ្លះទ្រង់នឹករំពឹងសព្វ ៗ ទៅ ក៏កើតទោមនស្សតូចព្រះទ័យ កាលបើទ្រង់តូចព្រះទ័យហើយ ច្រើនតែរករឿងកោសរួសបន្ទោសភីស្មៈមុនគេ ហើយធ្លាក់រាលដាលទៅដល់ទោណ ជាទីបំផុតគឺទ្រង់ចាប់ទោសថា អ្នកទាំងពីរប្រកបដោយក្ដីលំអៀង ប៉ុន្តែគំនិតរបស់ទ្រង់ក្នុងគ្រានោះ ៗ ប្រាថ្នាតែនឹងរកហេតុតែងតាំងកណ៌ ដែលជាមនុស្សគួរប្រោសរបស់ទ្រង់ ឲ្យទទួលតំណែងជាមេទ័ព ទ្រង់មិនពេញព្រះទ័យក្នុងការសង្គ្រាម ដែលលោកចមពលទាំងពីរបានធ្វើរួចមកហើយនេះសោះ ប៉ុន្តែតាមសេចក្ដីពិតគឺ ទុរយោធន៍ ឯងគិតអានមិនគាប់គួរតាមផ្លូវធម៌ យកតែតាមគំនិតព្រះអង្គឯងមួយ ឥតជឿស្ដាប់អ្នកណា សំគាល់ថាគំនិតព្រះអង្គ សុទ្ធតែត្រូវទាំងអស់គ្មានខុសសោះ ជាគំនិតដែលទ្រង់បានលាក់កំណប់ទុកមកយូរហើយ ។

កណ៌ដឹងថាពេញព្រះទ័យនឹងខ្លួនធ្វើការ ដើម្បីរក្សាព្រះទ័យ



ទ្រង់ឲ្យត្រជាក់ត្រជុំស្ងប់ស្ងាត់ ប្រាសចាកសេចក្ដីភ្ញាក់ផ្អើល ស្ដុតរន្ធត់ទើបទូលថា «ឲ្យថ្ងៃព្រឹកស្អែកនេះរះឡើងមកចុះព្រះករុណា ! ព្រះអង្គនឹងឃើញគុណបំណាច់ថ្វីដៃដែលកណ៌ធ្វើនោះសម្រេចទៅបាន, ទូលបង្គំនឹងសម្លាប់អរជុនក្នុងថ្ងៃស្អែកនេះ ឬបើអរជុនមិនស្លាប់ទេ ទូលបង្គំក៏ត្រូវស្លាប់ដោយសារថ្វីដៃអរជុនវិញ» ។

ទុរយោធន៍កាលបានឮពាក្យសច្ចាប្រណិធានដ៏មាំដូច្នេះហើយ ក៏មានព្រះទ័យស្ងប់ស្ងៀម ។ ពាក្យសច្ចាប្រណិធានដ៏មាំបែបនេះ ត្រូវព្រះទ័យទ្រង់ជាទីបំផុត ព្រោះជាគ្រឿងកំសួលលោហិតរបស់ទ្រង់ នឹងជាគ្រឿងបំពេញព្រះទ័យទ្រង់ឲ្យស្ងប់ ដោយទ្រង់សំគាល់ថា «ជ័យជម្នះនោះនៅជិត ៗ នេះឯង» វេលានេះព្រះទ័យទ្រង់បានស្ងប់ស្ងៀមជាច្រើនម៉ោង ស្ដេចចូលផ្ទំជាសុខសាន្តអស់រាត្រីកាល ។

លុះព្រឹកឡើង ទុរយោធន៍ទតឃើញព្រះអាទិត្យកំពុងរះឡើង មានព្រះទ័យរីករាយនឹកសង្ឃឹមថា មានជ័យជម្នះដោយសារថ្វីដៃកណ៌មេទ័ពថ្មីជាមិនខាន ។ រថសឹកកណ៌ មានសល្យរាជាជានាយសារថី លាន់ឮសូរគឹកកងពេញស្នាមយុទ្ធ ។ ទង់ជ័យលោកមេទ័ពថ្មីអណ្ដែតត្រសែតបោកបក់ទៅដោយខ្យល់យ៉ាងសង្ហា។ ក្នុងចិត្តលោកចមពលគិតប៉ុនប៉ងតែធ្វើសង្គ្រាមនឹងអរជុនតពីថ្ងៃមុន ដែលលើកលែងពាក់កណ្ដាល មិនទាន់ដឹងជាខាងណាឈ្នះ ខាងណាចាញ់ឲ្យដាច់ស្រេចនៅឡើយ, ភ្នែករំពៃគយគន់រកតែអរជុន កាលបើមិនបាន

ជួបប្រទះឃើញអរជុនឲ្យទាន់ចិត្ត ក៏គិតតែក្នុងចិត្តថា «ចម្បាំងក្នុងថ្ងៃដែលរួចមកហើយ ធ្វើឲ្យសត្រូវញញើតថ្វីដៃ ហេតុនោះបានជាសត្រូវគេចមុខបាត់លែងហ៊ានចូលមកតទល់គ្នាទៀត» ទើបនិយាយនឹងសារថីថា «អរជុនគេចអំពីការប្រយុទ្ធនឹងខ្ញុំជាប្រាកដ»។ សល្យៈឆ្លើយថា «លោកមុខជាបានជួបប្រទះនឹងអរជុនក្នុងកាលមិនយូរទេ, គេមិនមែនជាមនុស្សកំព្រញស្លូវស្លប់ខ្លបខ្លាចអ្នកណាទេ, លោកចូរប្រុងប្រយ័ត្នខ្លួនឲ្យមែនទែន ឲ្យផុតអំពីភ័យរបស់គេវិញល្អជាជាង» ។

កណ៌ធ្វើមុខតឹងខឹងខ្លាំង នៅពេលបានស្តាប់ពាក្យទាំងនេះ ហើយបង្គាប់ឲ្យបររថទៅយ៉ាងរហ័ស ទៅមិនទាន់ឆ្ងាយប៉ុន្មាន ស្រាប់តែបានជួបប្រទះនឹងយុធិស្ឋិរ គង់នៅលើរថសឹកដ៏វិចិត្រ មកនៅរាំងទទឹងមុខរថសឹកគេ។ មានពួករាជបរិស័ទដ៏ក្លៀវក្លាមួយកងលើកចូលវាយកាត់ពាក់កណ្តាល រវាងកណ៌ និងយុធិស្ឋិរ ប្រឹងវាយបង្អន់កម្លាំងនៃការរុកចូលមកនោះ ឲ្យទន់ខ្សោយថយចុះ ប៉ុន្តែដៃរបស់កណ៌ដ៏ទ្រង់នូវកម្លាំងមហិមា បានប្រហារពួកពលទាំងនោះ ឲ្យខ្ចាត់ខ្ចាយទៅដោយងាយ ។ តមកពួកបញ្ចាលប្រឹងប្រែងចូលវាយកាត់មួយលើកទៀត ប៉ុន្តែត្រូវកណ៌វាយខ្ចាត់អស់ទៅដូចមុន ។ គ្មានអ្នកណាមករាំងទទឹងមុខកណ៌បានឡើយ គ្មានអ្វីមកបង្អន់កម្លាំងក្លាហានរបស់កណ៌ឲ្យថយខ្សោយបានឡើយ គេចេះតែសម្រុកចូលវាយយុធិស្ឋិរបីដូចជាអគ្គិដ៏រុងរឿង ។ យុធិស្ឋិរបានទទួលទប់ទល់ការចោមវាយ



នោះ បីដូចជាភ្នំក្រំថ្មឃឹតធ្នូរបស់ទ្រង់ថ្លែងចេញខ្ទាប់ទៅត្រូវឆិតស្មាឆ្វេងនៃកណ៌ ។ កណ៌ថ្លែងសរតបមកវិញត្រូវអាវក្រោះដាច់ដាចរហែកបាត់អស់នៅតែខ្លួនទទេ យុធិស្ឋិរចេះតែខំតស៊ូ ឥតលះលាថយ សេះរបស់ទ្រង់ក៏ត្រូវអាវុធស្លាប់ម្តងមួយ ៗ ទង់ជ័យមហារាជត្រូវអាវុធដាច់ថ្វិលធ្លាក់ចុះមកដល់ដី រថសឹកបាក់ខ្ទេចខ្ទី ប៉ុន្តែទោះបីដូច្នោះ យុធិស្ឋិរ នៅតែខំតស៊ូឥតរាថយទាល់តែត្រូវសរមួយកូនដែលកណ៌បាញ់សំដៅមកលោហិតហូរដាប មានអាការៈរង៉ាប់រងើងងឹតមុខ ពួកទាហានអ្នកតាមហែស្តេច បានសែងទ្រង់នាំចេញអំពីទីយុទ្ធភូមិជាប្រញាប់ យុធិស្ឋិរទោះបីត្រូវសរដល់ម្លឹងហើយ គ្មានអន់ថយសេចក្តីក្លាហាន ឬខ្សោយកម្លាំងកាយបន្តិចសោះ បើមានថយគឺថយរឿងដែលទ្រង់ត្រិះរិះគិតហេតុការណ៍នោះ ៗ ច្រើនជ្រុលពេក ព្រោះចិត្តធ្វើការហួសបន្ទុកអាចឲ្យអន់ថយខ្លះ, ការថមថយទាំងនេះ ធ្វើឲ្យទ្រង់ទោមនស្សតូចព្រះទ័យ នឹងក្រោធខ្លាល់មួយស្របក់ ៗ ទ្រង់ចូលផ្ទំក្នុងបារាំសម្ងំចាំមរណកាល មិនមែនផ្ទំព្រោះឈឺចាប់រាងកាយទេ ឈឺចាប់ដោយសេចក្តីក្តៅក្តួលព្រះទ័យរម្ងាប់មិនបាន ក៏ទ្រង់ផ្ទំធ្មេចព្រះនេត្រខំអត់សង្កត់ហាក់ដូចជាផ្ទំស្កល់ ។ អរជុនចូលទៅក្នុងបារាំដើម្បីពិនិត្យមើលឲ្យដឹងថា ព្រះជេដ្ឋាមានរបួសស្លាកស្នាមធ្ងន់ប៉ុណ្ណា ឃើញទ្រង់ផ្ទំស្កល់ក៏សន្សឹម ៗ ថយចេញមកវិញ យុធិស្ឋិរស្រែកសួរតាមក្រោយថា «អរជុន ឬ ?» ។

«ព្រះករុណា» អរជុនឆ្លើយ ។

«សម្លាប់កណ៌បានហើយឬនៅឡើយទេ ?» យុធិស្ឋិរសួរ ។

អរជុនត្រឡប់ចូលទៅក្នុងបារាំវិញ ក្រឹស្ណៈក៏ចូលតាមទៅផងទូលថា «នៅ ! នៅព្រះករុណា ! មិនទាន់សម្លាប់វាបានទេ»។ អរជុនរៀបនឹងទូលរឿងអ្វី ៗ តទៅទៀត ប៉ុន្តែឃាត់ចេញ ហើយអធិប្បាយឲ្យយុធិស្ឋិរស្តាប់ថា «អរជុនបានធ្វើតស៊ូក្នុងភាគម្ខាងនៃស្នាមយុទ្ធនិងដោះដៃមកប្រយុទ្ធជាមួយកណ៌មិនបាន ប៉ុន្តែបានតាំងប្តេជ្ញាថានឹងសម្លាប់កណ៌ឲ្យបានក្នុងថ្ងៃនេះជាមិនខាន»។

យុធិស្ឋិរ កាលបានស្តាប់ពាក្យនេះហើយ ក៏ខ្វាល់ត្លូងត្រាស់កោសរូសសិកសៀកឲ្យអរជុនថា «ម្តេចអ្នកឯងតែងកាយយ៉ាងអ្នកចម្បាំង, មានមួកពាក់នៅលើក្បាល, មានដៃកាន់ធ្នូសិល្ប៍ ហើយមកគេចវេះអំពីមុខកណ៌ ដ៏ជាសត្រូវកំណាចរបស់អ្នកឯង ធ្វើការបាក់ដូចជាស្រីយ៉ាងនេះ, ចូរប្រគល់ធ្នូសិល្ប៍របស់អ្នកឯងឲ្យអ្នកដែលគ្រាន់បើជាងខ្លួនទៅវិញទៅ ហើយចូរពួនមុខតាមក្បៀនកោះដ៏ងងឹត ៗ ណាមួយ ក្នុងខណៈដែលសត្រូវដ៏កំណាចមកជិះជាន់យាយីមិត្រសម្លាញ់បងប្អូនអ្នកឯងក្នុងកណ្តាលស្នាមយុទ្ធ ហើយចាំអើតកលបមើលអំពីចម្ងាយទៅ»។

អរជុនញាក់ញ័រ ដោយទោសៈទប់ពុំឈ្នះនៅវេលាដែលបានឮពាក្យសិកសៀតដាក់ ដូចជាមិនបងប្អូនយ៉ាងនេះ ដៃក៏ស្ទាបរកដង



ក្របីដោយមនោវិញ្ញាណមិនបានបង្គាប់ឲ្យធ្វើសោះ ហូតក្របីក្រាកចេញអំពីស្រោមក្នុងខណៈដែលភ្លើងទោសៈដុតពោលរាលនោះ ភ្លេចគិតថា អ្នកដែលនិយាយអម្បាញ់មិញនេះ ជាព្រះញាតិរបស់ខ្លួន ។ ក្រឹស្ណៈក្រឡេកឃើញអាការៈមិនស្រួលក្រែងនឹងកើតអន្តរាយធំ ក៏និយាយរំឭកស្មារតីអរជុនឲ្យដឹងខ្លួន ។ អរជុនដាក់ក្របីភ្លាម មានទឹកមុខស្លេកស្លាំងដោយនឹកអៀនខ្មាស នឹងអាការៈដែលខ្លួនធ្វើជ្រួសជ្រលួសទៅមិនគួរសម ទើបក្រាបចុះទៀបបាទមូលនៃព្រះជេដ្ឋាធិរាជ សូមខមាទោសដែលទោសៈវានាំទៅឯង ៗ ដូច្នោះ ។ យុធិស្ឋិរក៏ប្រទានទោសឲ្យព្រះអនុជ ដោយស្មោះអស់ពីព្រះទ័យ ស្រវាឱបហើយត្រាស់ថា «ការដែលរៀមធ្វើឲ្យប្អូនអាក់អន់ស្រពន់ចិត្តនោះមិនមែនជាការកំហុសរបស់ប្អូនទេ បណ្តាលហេតុមកពីរៀមមានសេចក្តីឈឺចិត្តក្នុងរឿងផ្សេង ៗ មកទម្លាយនិស្ស័យសុភាពរបស់រៀមឲ្យវិនាសអស់ទៅ ប៉ុន្តែឥឡូវនេះ សូមឲ្យប្អូនលុបលាងកត្តុឡកម្មទាំងនេះចេញដោយមេត្តាចិត្តរបស់រៀមចុះណាប្អូន ! អ្នកទទួលពររបស់រៀមហើយ ចូរទៅកម្រាបសត្រូវរបស់អ្នកឲ្យជ្រះស្រឡះចេញទៅ ។

អរជុនទូលតបទាំងអស្សុជលរលោងក្នុងនេត្រថា«ទូលបង្គំនឹងមិនដោះអាវក្រោះនេះចេញមុនពេលដែលនឹងសម្លាប់កណ៌បាន» ។ ដោយហេតុតែពាក្យប្តេជ្ញានេះ អរជុនក៏បររថសឹកទម្លុះទម្លាយចូលទៅក្នុងកងទ័ពកុរុ ដ៏ក្រាស់ ។ កណ៌លេចធ្លោចេញមុខមកទទួលរះគ្នា

នឹងអរជុន ។ អ្នកចម្បាំងទាំងពីរដែលធ្លាប់តែផ្ចាលផ្ចាញ់គ្នាជាញយ ៗ មកហើយនោះ បានចូលផ្ចាញ់គ្នាក្នុងគ្រានេះម្តងទៀត មិនចេះរានឹងគ្នាដូចកាលរួចមកហើយពីមុន ៗ ។ សររបស់អរជុនធ្លាក់ព្រោងព្រាតដូចគ្រាប់ភ្លៀងទាល់ តែខ្សែបន្លោះធ្នូដាច់ ដោយហេតុខំយឹតខ្លាំងពេកមិនដែលមានអ្នកចម្បាំងណាធ្លាក់ខ្លួននៅក្នុងគ្រោះថ្នាក់ ដ៏កាចយ៉ាងនេះសោះឡើយ ។ អរជុនស្រែកសុំឲ្យគេបង្អង់ច្បាំងមួយរំពេចសិនដើម្បីនឹងផ្លាស់ខ្សែបន្លោះធ្នូ ។ តាមច្បាប់ខត្តិយប្រពៃណីទំនៀមទម្លាប់អ្នកមច្បាំងនោះលោកថា មិនឲ្យប្រទូសរ៉ាយសឹកដែលឥតកាន់អាវុធនៅដៃ ឯអរជុនក៏បានអាងដល់ប្រពៃណីនៃអ្នកចម្បាំងត្រង់រឿងនេះដែរ ប៉ុន្តែកណ៌ដែលមានចិត្តគុំកួនគិតតែយកជីវិតអរជុនឲ្យបាននោះ ក៏មិនត្រូវការនឹងប្រតិបត្តិតាមច្បាប់ខត្តិយប្រពៃណីនោះសោះ ចាប់យកឱកាសនោះជាផលកម្រៃ ក៏យឹតធ្នូដ៏ធ្ងន់បំផុតបាញ់តម្រង់ទៅអរជុនព្រួស ៗ ដោយបំណងនឹងយកជីវិតអរជុនឲ្យបានមុនដែលគេមានឱកាសកាន់អាវុធការពារខ្លួន ។ អរជុនអន់ប្រៀបក្នុងជើងចម្បាំងមួយស្របក់ អត់ទ្រាំការប្រហាររបស់សត្រូវពេញរបុងតាមកម្លាំងដែលអាចទ្រាំបាន លុះជួសជុលខ្សែបន្លោះធ្នូបានដូចដើមហើយ ក៏បាញ់សងទៅវិញឥតបីបើគណនា ប៉ុន្តែសរអរជុនដែលថ្លែងចេញទៅទាំងប៉ុន្មានមិនសូវបានផលទេ ដូចជាកូនសររបស់កណ៌ដែរ ។ ការតស៊ូនោះស្មើគ្នាទាំងពីរខាង មើលទៅទំនងជាលើកលែង



ឃ្លាញរាថ្វីដៃគ្នាទៀត ប៉ុន្តែដោយហេតុបណ្តាលឲ្យកង់រថរបស់កណ៌ជាប់ផុងវេមិនរួច កណ៌បានស្រែកសុំឲ្យបង្អង់ច្បាំងសិន ដោយអាងដល់ខត្តិយប្រពៃណីដែលគេធ្វើល្មើសមកហើយអម្បាញ់មិញ ។

វេលានោះ បានឱកាសល្អដែលអរជុននឹងតបស្នងឲ្យដល់ចិត្តវិញ ។ ក្រឹស្ណៈនិយាយពាក្យសឹកសៀតឲ្យកណ៌ថា «អើ វេលានេះអ្នកអាងដល់ច្បាប់ទម្លាប់ខត្តិយប្រពៃណី ដែលអ្នកបានប្រព្រឹត្តល្មើសក្នុងកាលអម្បាញ់មិញនេះឬ ? មនុស្សយ៉ាងអ្នកនឹងមកទាក់ទិនអី ដោយច្បាប់នៃកិត្តិយសនោះ ? អ្នកបានរក្សាច្បាប់នៃកិត្តិយសទុកឬទេ ? ក្នុងកាលដែលអ្នកព្រមទាំងសកុនិ បាននាំគ្នាប្លន់យកស្រីង្គារទ្រព្យសម្បត្តិរបស់យុធិស្ធិរ ? អ្នកបានរក្សាច្បាប់នៃកិត្តិយសទុកឬទេ ក្នុងកាលដែលអ្នកប្រមាថមើលងាយទ្រៅបទីក្នុងទីប្រជុំនៃរដ្ឋមន្ត្រីនោះ ? អ្នកបានប្រតិបត្តិតាមច្បាប់នៃកិត្តិយសឬទេ ក្នុងកាលដែលគប់គិតសមគំនិតគ្នាជាមួយគ្នានឹងអាទរពល សន្តានពាលទាំង ៦ នាក់ ព្រួតវាយអភិមន្យុតែម្នាក់ឯងទាល់តែស្លាប់បង់ទៅ ធ្វើអាការៈដូចជាចោរនោះ ?»។ កណ៌នឹកអៀនខ្មាសខ្លួនយ៉ាងខ្លាំងលែងអង្វរគេទៅទៀតលោតចុះពីលើរថសឹកភ្លាម ចូលច្បាំងដោយអាការៈដើរជើង ខាងអរជុនវេលានោះមានប្រៀបក្នុងជើងចម្បាំង យឹតធ្នូទិព្វរបស់គេតំរង់ក្បាលសត្រូវ ហើយក៏ថ្លែងខ្វាប់ចេញទៅត្រូវកណ៌ដួលខ្ពោកលើផែនពសុធា ហើយថែមទៅទៀតទាល់តែកណ៌ក្រោកលែងរួច ។

## ភាគទី ១៧

# អវសាននៃសង្គ្រាម

កាលកណិដល់នូវមរណភាពទៅហើយ កងទ័ពកុរុក៏ចោលទទេគ្មានមេអ្នកនាំទ័ពទៅទៀត ទាហានរត់ខ្ចាត់ខ្ចាយទៅទីទៃ ៗ និងកើតចលាចលស្ទើរតែប្រែក្លាយទៅជាការអំពល់ធំ ។ ក្រិបាចារ្យ អ្នកមានប្រាជ្ញា បានចូលទៅគាល់ទុរយោធន៍ទូលថា «កងទ័ពរបស់ព្រះអង្គវេលានេះ គ្មានមេទ័ពនឹងបង្គាប់បញ្ជាទេ ធម្មតាកងទ័ពបើគ្មានអ្នកបង្គាប់បញ្ជាការទេ សូម្បីជាកងទ័ពដែលល្អសំខាន់បំផុត ក៏ស្មើដូចជាកងទ័ពចោរ ឥឡូវនេះ អរជុនគ្មានអ្វីមកនៅទទឹងទើសដៃគេបានទេ ដៃគេចេះតែត្រាយឲ្យវាលល្វឹងដូចយ៉ាងត្រាយស្មៅ តាំងអំពីនោះមកដល់ឥឡូវនេះ បានលះបង់សាច់ឈាមក្រៃល ប្រហែល ៗ គ្នាទាំងពីរខាង ប៉ុន្តែផលដែលប៉ុនប៉ងក្នុងទីបំផុត នៅមិនទាន់មើលឃើញសោះ សូមឲ្យពួកអ្នកដែលបានរួចអំពីមរណៈមកហើយ ដរាបដល់វេលានេះ ចូរឲ្យគេរួចរហូតទៅចុះ កុំបោះបង់ចោលវង្សត្រកូលដ៏ក្លាហានរបស់ព្រះអង្គឲ្យសាបសូន្យទៅឡើយ នៅមានវេលានឹងកែខៃអ្វី ៗ តទៅទៀតបានខ្លះនៅឡើយ សូមឲ្យធ្វើសញ្ញាសន្តិភាពស្ងប់សឹកត្រឹមតែប៉ុណ្ណឹងទៅចុះ ដ្បិតបាឫទ័យយុធិស្ឋិរ សឹងតែប្រកបដោយមេត្តាករុណាច្រើន មុខជាទ្រង់មិនបដិសេធន៍សេចក្តីសុំស្ងប់



សឹកនេះចោលឡើយ អាចនឹងចូលនិយាយការគ្នាបាន មិនកំណត់ថាវេលាណាទេ»។

ទុរយោធន៍ «ក្រិបះអើយ ! សំដីរបស់អ្នកគួរស្តាប់ហើយជាសំដីរបស់អ្នកប្រាជ្ញមែន អ្នកធ្លាប់តែធ្វើជាមនុស្សកណ្តាលតែងនិយាយបញ្ចុះបញ្ចូលអ្នកទាំងពីរខាងឲ្យសះជានឹងគ្នា តាំងពីដើមដៃរហូតមកដល់ឥឡូវនេះ ប៉ុន្តែខ្ញុំគិតក្រែងថា ពាក្យណែនាំរបស់អ្នកមិនត្រូវនឹងបែបលោកនិយមបច្ចុប្បន្ននេះ ខ្ញុំមិននឹកសង្ឃឹមសោះឡើយថាយុធិស្ឋិរនឹងទទួលយកនូវមេត្រីភាពរបស់យើងទៀត ឬខ្ញុំមិននឹកឃើញថា ភីមនឹងភ្លេចពាក្យប្តេជ្ញារបស់គេ ឬខ្ញុំមិននឹកឃើញថាអរជុននឹងអហោសិកម្មរឿងមរណភាពនៃអភិមន្យុជាបុត្រឡើយ មួយទៀតខ្ញុំនឹងធ្វើមិនដឹងមិនឮ អំពីរឿងព្រះញាតិអ្នកធំ ៗ ដែលខ្ញុំនាំយកមកឲ្យស្លាប់បាត់បង់អស់ទៅជាច្រើនអង្គនោះ ដូចម្តេចកើត ? ខ្ញុំក្សត្រិយ៍ទ្រង់រាជ្យ នឹងទៅលុតជង្គង់សម្ពរសុំសេចក្តីមេត្តាករុណាពីគេដូចម្តេចកើត ? រឿងនេះជាទីអាម៉ាស់មុខខ្ចូចបង់កេរ្តិ៍ឈ្មោះ ជាងការបរាជ័យចាញ់ចាលក្នុងកណ្តាលស្មាមយុទ្ធទៅទៀត, សល្យៈ ព្រះរាជានៃក្រុងមាទ្រៈ នឹងធ្វើជាអ្នកនាំទ័ពរបស់យើងក្នុងថ្ងៃនេះ, យើងនឹងមិនបន្ទូរបន្ថោះធ្នូរបស់យើងទេ, ដរាបណាយើងនៅសល់ទាហានតែម្នាក់ចូលតដៃនឹងគេ ដរាបនោះ ទើបយើងទម្លាក់ធ្នូចុះឈប់ច្បាំង ។

ចំណែកការស្លាប់នៃកណិជាទីរីករាយនៃពួកបាណ្ឌពយ៉ាងក្រៃ

លែង ព្រោះគេយល់ថាមេទ័ពថ្មីនោះប្រៀបដូចជាសេចក្ដីវាយការណ៍របស់រាជទូតតែប៉ុណ្ណោះ គេយល់ទៀតថា កម្លាំងខាងសឹកសត្រូវខ្សត់ខ្សោយទន់ទាបណាស់ទៅហើយ ។ ព្រះអនុជនៃយុធិស្ឋិរទាំងអស់អង្គនាំគ្នាចេញទៅនៅអមអង្គយុធិស្ឋិរ ដើម្បីមិនឲ្យមេទ័ពថ្មីវាយបាន ប៉ុន្តែយុធិស្ឋិរត្រាស់ថា «ម្នាលអនុជទាំងឡាយ ! អ្នកទាំងឡាយបានធ្វើនូវភាគនៃការសង្គ្រាម ជាចំណែករបស់ខ្លួនរួចស្រេចហើយ ដោយសេចក្ដីក្លាហាន, នៅថ្ងៃនេះ យើងសុំខ្លួនជាអ្នកនាំទ័ពចូលទៅកម្រាបពួកកុរុ យើងចាត់ឲ្យសាត្យកិច្ចៈជាអ្នករក្សាស្លាបស្ដាំ, ចាត់ឲ្យធ្រុស្ដ-ទ្យុម័នជាអ្នករក្សាស្លាបឆ្វេងរបស់យើង ចាត់ឲ្យភីមជាអ្នកនាំទ័ពស្រួច ចាត់ឲ្យអរជុនជាអ្នកនាំទ័ពក្រោយ, ឯខ្លួនយើងនឹងកាន់កាប់ទ័ពធំនៅកណ្ដាលដោយចាត់របៀបក្បួនទ័ពយ៉ាងនេះ យើងសង្ឃឹមថា មុខជាយកជ័យជម្នះបាន ដោយការចូលវាយតែមួយគ្រា» ។

យុធិស្ឋិររក្សាវាចារបស់ព្រះអង្គទុកឲ្យគង់តាមន័យដែលពោលមកហើយបានស្ដេចនាំទ័ពចូលតស៊ូដោយក្លាហាន ជាសួស្ដីជ័យសិទ្ធិសម្រាប់ពួកបាណ្ឌព ដែលបានព្រះរាជារបស់គេ ជាចមទ័ពក្នុងថ្ងៃជាទីបំផុតនៃការចម្បាំង ។ សង្គ្រាមថ្ងៃនេះគេច្បាំងគ្នាយ៉ាងផ្ដេសផ្ដាសណាស់ មិនត្រូវទៅតាមរបៀបទេ ។ ប្រយុទ្ធគ្នាបានតែមួយស្របក់ ៗ រកកលជ្រួលច្របល់នឹងបែកកង នៅទីជុំវិញលោកមេទ័ពទាំងពីរខ្ទួលខ្ទាញ់ត្រឡប់ត្រឡិនដូចជាព្យុះព្យោមា ឮតែសូរសន្ធឹកតស៊ូគ្នា។



សល្យៈតស៊ូ គ្រាក់ ៗ យ៉ាងអស់សង្ឃឹម ។ យុធិស្ឋិរ ជាស្ដេចសឹកទ្រង់នូវធម្មានុភាពបានច្បាំងដោយក្លាហាន កូនសរដែលទ្រង់ថ្លែងចេញទៅព្រួស ៗ ញឹកដូចគ្រាប់ភ្លៀងទៅធ្លាក់លើសល្យៈ អ្នកដល់នូវព្រហ្មលិខិតក្នុងថ្ងៃនោះ ។ ទង់ជ័យកំពូលពលរបស់កុរុត្រូវសរដាច់ប៊ិត ៗ ហើរប្រុយ ៗ ដូចស្លឹកឈើទុំជ្រុះ ។ ពួកកុរុត្រូវគេវាយបែកខ្ញែកគ្រាកថយចេញទៅ ហើយត្រឡប់រួមចូលគ្នាជាកងវិញ តែបែបនេះជាច្រើនដងជាច្រើនគ្រា មិនយូរប៉ុន្មាន សល្យៈ មេទ័ពធំខាងកុរុត្រូវអាវុធរលើងគ្រេងទៅទៀត ។ ពួកបាណ្ឌពសង្គ្រុញចូលកាប់កាត់វាយវាត់ឆ្វេងស្ដាំ ធ្វើឲ្យកងទ័ពកុរុបរាជ័យវិនាសខ្ចាត់ខ្ចាយវាលធេងទៅ ។ សហទេពចូលប្រហារអ្នកលេងស្កាដោយកលកោង គឺសកុនិដែលមានជីវិតរស់នៅដល់ថ្ងៃនោះ ។ ភីមចូលវាយទុហសាសនៈស្លាប់ដោយគទាវុធដ៏ធំរបស់គេ ហើយកាត់កហុតឈាមតាមពាក្យប្ដេជ្ញាដែលគេបានតាំងសច្ចាប្រណិធានទុក «អើ! អើ! យើងមិនដែលផឹកអ្វីផ្អែមដល់ម្ល៉េះទេ»។ ចំណែកទុរយោធន៍បានស្ដេចគេចរត់ចេញអំពីស្នាមយុទ្ធទៅតែមួយអង្គឯង ។ អស្វត្ថាម័ន បុត្រទោណ ដែលល្បីថាស្លាប់ទៅហើយ, ព្រាហ្មណ៍ក្រិបាចារ្យ និងព្រាហ្មណ៍ខ្មាន់ធ្នូឈ្មោះកិត្តិវរម័ន ទាំងបីនាក់នេះត្រូវគេចាប់ខ្លួនបានជាឈ្លើយសឹក ។

ព្រះបាទទុរយោធន៍ ក្រុងហាស្ដិនបុរ ស្ដេចគេចរត់យកតែជីវិតមួយព្រះអង្គឯង នៅពេលដែលទ្រង់រត់នៅអំពីទីសមរភូមិនោះ ទ្រង់

គិតថាគួរតែយកដំបងកាយសិទ្ធិសម្រាប់អង្គជាប់ទៅផង ព្រោះខ្លាចក្រែងសត្រូវនឹងដិតដាមតាមទៅធ្វើអន្តរាយ គ្រាន់នឹងបានជាគ្រឿងការពារខ្លួន ទើបទ្រង់យកដំបងនោះជាប់នៅដៃទៅផង លុះទៅមិនជាឆ្ងាយប៉ុន្មានអំពីទីសមរភូមិ មានត្រពាំងទឹកជ្រៅ ទុរយោធន៍បានចុះទៅអាស្រ័យពឹងពួនលាក់ខ្លួនក្នុងទឹកនោះ សម្រាកជាបណ្តោះអាសន្នសិន ទម្រាំតែបានឱកាសស្រួលនឹងគេចរត់ទៅទៀត ទ្រង់ចេះវិជ្ជាមុជទឹកបានយូរ ៗ សំកាំងសំកកនៅក្នុងទឹកបានច្រើន ៗ ថ្ងៃដូចជាត្រី ហេតុដូច្នោះកាលទ្រង់ចុះទៅក្នុងត្រពាំងនោះ បានមុជទៅនៅសម្ងំក្រោមទឹក ដើម្បីលាក់ខ្លួនពួនឲ្យផុតពីភ័យ ។

គ្រានោះ មានល្បែងគគ្រឹកគគ្រេងលេងសើចសប្បាយរីករាយពេញទាំងបន្ទាយបាណ្ឌព ។ ប៉ុន្តែព្រះហឫទ័យនៃព្រះបាទយុធិស្ឋិរនៅវេលានោះ គ្មានសប្បាយរីករាយនឹងគេបន្តិចសោះ ទ្រង់ចេះតែស្រងូតស្រងាត់ ព្រួយព្រះកមលដោយទ្រង់នឹកស្តាយស្រណោះអាឡោះអាល័យដល់ពួកព្រះញាតិ ដែលពិឃាដស្លាប់បាត់បង់ទៅទាំងនោះ ព្រោះអ្នកស្លាប់ទៅទាំងពីរខាងសុទ្ធតែជាព្រះញាតិរបស់ព្រះអង្គទាំងអស់ទ្រង់ជាប់ប្រតិព័ទ្ធដោយអំណាចចំណងនៃលោហិតដោយចំណងនៃប្រទេស ដោយចំណងនៃក្តីស្នេហា ព្រោះមូលហេតុទាំងនេះ នៅវេលាដែលអ្នកដទៃ គេរីករាយខ្សេវខ្សារ ព្រះបាទយុធិស្ឋិរចេះតែស្ងួតស្ងប់ព្រះហឫទ័យ ទ្រង់កាន់ទុក្ខឲ្យពួកព្រះញាតិវង្សទាំង



ពីរខាងដែលចែកស្ថានទៅ ទ្រង់សម្តែងទុក្ខក្នុងព្រះហឫទ័យឲ្យប្រាកដហាក់ដូចជាប្រាប់គេថា «មើលចុះណា យើងជាក្សត្រិយ៍ក្នុងពពួកអ្នកស្លាប់!»។

គ្រានោះ មានមនុស្សមកក្រាបទូលថា បានប្រទះឃើញទុរយោធន៍នៅក្នុងទឹកត្រពាំង ។ ដំណឹងនេះនាំឲ្យព្រះអង្គបានបន្ធោបង់នូវសេចក្តីទុក្ខសោកសៅ ក្នុងព្រះហឫទ័យចេញ មិនមែននាំឲ្យព្រះអង្គមានព្រះទ័យប៉ុនប៉ងនឹងចាប់អរិរាជសត្រូវដ៏ធំនោះឡើយ ព្រោះទ្រង់យល់ថា ជាហេតុឲ្យមានឱកាសដល់ទ្រង់ នឹងបានធ្វើការសម្រួមសម្រួបឲ្យស្ងប់សឹក ដើម្បីទទួលយកអាណាចក្រឥន្ទ្របថរបស់ព្រះអង្គដែលខូចបង់ទៅនោះមកវិញដោយស្រួល និងប្រគល់រាជអាណាចក្រហស្តិនបុរដែលទ្រង់វាយបាននោះ ឲ្យទៅទុរយោធន៍វិញ ព្រះហឫទ័យទ្រង់ប្រកបដោយមេត្តា ឥតគិតព្យាបាទសងសឹកវិញសោះ មិនមែនតែក្នុងវេលានេះទេ សូម្បីពីដើមមកក៏មិនដែលគិតព្យាបាទដល់ម្តងដែរ របស់ដែលទ្រង់ត្រូវការជាបំផុតនោះ គឺទ្រង់ប៉ុនប៉ងតែនឹងសុំយករាជអាណាចក្ររបស់ទ្រង់ ដោយសិទ្ធិនៃសាលោហិតមកវិញតែប៉ុណ្ណោះទ្រង់ឥតត្រេកអរនឹងរបស់ដែលទ្រង់វាយបាននោះទេ ឯព្រះហឫទ័យទ្រង់ មុខជានឹងសប្បាយរីករាយនៅវេលាដែលបានឃើញទុរយោធន៍គ្រប់គ្រងព្រះនគរជាសុខ ហេតុនោះកាលទ្រង់បានជ្រាបទីកន្លែងដែលទុរយោធន៍ទៅពួននោះហើយ ក៏

ស្តេចយាងជាប្រញាប់ទៅឯត្រពាំងទឹកនោះ ស្រែកហៅចេញព្រះនាមទុរយោធន៍ពេញព្រះសូរសៀង ។ ទុរយោធន៍ មុនដំបូងមិនព្រមឆ្លើយតប លុះខាងក្រោយបានឮយុធិស្ធិរ បបួលឲ្យឡើងមកច្បាំងគ្នាតតូ ទើបឆ្លើយតបថា «ចូរយករាជអាណាចក្រខ្ញុំចុះ, ចូរសោយរាជ្យសម្បត្តិឲ្យបានសុខចុះ, ចូរលែងខ្ញុំឲ្យនៅតាមទំនើងចិត្តខ្ញុំចុះ, ខ្ញុំនឹងទៅនៅព្រៃគ្រប់គ្រងវ័យដែលនៅសល់ក្នុងអាយុកាលរបស់ខ្ញុំ ដោយការចម្រើនភាវនា និងបំពេញតបៈ» ។

យុធិស្ធិរ «ខ្ញុំនឹងមិនទទួលយករបស់ដែលខ្ញុំគ្មានជ័យក្នុងទីចម្បាំងទេ, ខ្ញុំទទួលយករបស់អំណោយនេះមិនបានទេ »។

ទុរយោធន៍ «បើទ្រង់សន្យាថានឹងច្បាំងតតូមែន ខ្ញុំនឹងឡើងទៅឥឡូវនេះ»។

យុធិស្ធិរឆ្លើយទទួលថាព្រមធ្វើតាមសន្យានោះជាប្រាកដ ប៉ុន្តែទុរយោធន៍នៅរារែកស្ទាក់ស្ទើរមិនចង់ឡើងមក ។

ភីមកើតទោសៈឡើង ដោយហេតុទុរយោធន៍យឺតយូរក្រឡើងពីក្នុងទឹកក៏ស្រែកគំរាមទៅថា «បើទ្រង់មិនឡើងមកអំពីទឹកឥឡូវនេះទេ យើងមុខជានឹង ... ... ,នៃអ្នកក្រពើប្លម ! យើងនឹងលោតចុះទៅអូសយកខ្លួនឡើងមកឥឡូវនេះ» ។

ទុរយោធន៍ក៏ម្នីម្នាឡើងមកលើគោក ។ ភីមសើចឮ ហះ ហាយ ៗ នៅវេលាដែលឃើញព្រះភក្ត្រទុរយោធន៍ប្រឡាក់ផុកស្រមក និង



ទទឹកខ្លួនជោក ។ ហះ ហៃ ៗ យើងនឹងបន្លែប្រការអស់សំណើចរបស់យើងឲ្យទៅជាការយំសោកវិញ ។

ពាក្យប្តេជ្ញារបស់ភីមបានតាំងទុកក្នុងចិត្ត រហូតដល់អស់អាយុកាល គឺថាប្តេជ្ញានឹងសម្លាប់ទុរយោធន៍ឲ្យបាន ហេតុនោះការតស៊ូគ្រានេះទើបគេបណ្តោយ ឲ្យភីមជាដំបូងដៃចូលប្រយុទ្ធនឹងទុរយោធន៍ ។ អ្នកចម្បាំងទាំងពីរប្រសប់ស្ទាត់ក្នុងការប្រើដំបង សឹងល្បីនាមដូចគ្នាទាំងគូ ។ អ្នកទាំងពីរជាសត្រូវនឹងគ្នា ហើយបានប្តេជ្ញាថានឹងយកជីវិតគ្នាទៅវិញទៅមក ។ គ្រានោះ អ្នកចម្បាំងទាំងពីរប្រាណបានចូលប្រយុទ្ធគ្នាដណ្តើមយកជ័យដូចក្របីព្រៃ មុខអ្នកទាំងពីរមានដំណក់ឈាមប្រឡាក់ជុំ ៗ ភ្នែកក្រហាមដូចភ្នែកល្អូត សម្លឹងសម្លក់ ហាក់ដូចជានឹងស្ទុះទៅស៊ីសាច់គ្នា លោលោតវាយវាត់គ្នា នឹងគេចកែប្រែខ្លួនបែកពពុះមាត់ស្គុលមួយខណៈនោះ ទុរយោធន៍ជិតតែនឹងកាច់ភីមបាន គឺទ្រង់វាយញាំងទៅត្រូវក្បាលជ្រុលទ្រេតទ្រោតជិតនឹងដួល ប៉ុន្តែមិនយូរប៉ុន្មាន ភីមទប់ខ្លួនឡើងវិញបាន វាយសងទៅវិញត្រូវក្បាលជង្គង់ទុរយោធន៍គ្រង់គ្រាប់អង្គញ់បែកល្អិត ទុរយោធន៍ដួលផ្កាប់មុខស្រប៉ូប ។ សេចក្តីប្តេជ្ញារបស់ ភីមក៏បានសម្រេច តាមដែលគេតាំងសច្ចាប្រណិធានទុក ។ ភីមញាក់មុខញាក់មាត់រាំរេជុំវិញទុរយោធន៍ ហើយពោលថា «នេះឈ្មោះថា បានធ្វើការសងសឹកជំនួសទ្រៅបទីក្នុងទីបំផុតហើយ »។

យុធិស្ឋិរខ្ទាល់នឹងភីម ដែលពោលផ្តន្ទាសត្រូវដួលដេក ហើយត្រាស់ឲ្យនាំខ្លួនចេញពីទីនោះ ដើម្បីកុំឲ្យធ្វើវិការជាហេតុចង្អៀតចង្អល់ចិត្តទុរយោធន៍ ។ កាលភីមចេញទៅផុតហើយ យុធិស្ឋិរក៏លុតជង្គង់ក្បែរអង្គទុរយោធន៍ ហើយត្រាស់ថា «ទ្រង់នៅជាក្សត្រិយ៍ និងនៅជាម្ចាស់របស់ខ្ញុំ»។

ប៉ុន្តែវេលានោះ ព្រះនេត្រទុរយោធន៍ធ្មេចជិតទៅហើយ វិញ្ញាណចេញផុតពីរាងកាយទៅហើយ ទ្រង់មិនដឹង មិនឮ មិនឃើញនូវការលុតជង្គង់សម្តែងសេចក្តីគោរពអំពីបាណ្ឌវរាជនេះទេ ។ អ្នកដែលធ្វើដូច្នេះនឹងមិនបានទទួលពាក្យតប ឬពាក្យអំណរគុណអំពីទ្រង់ឡើយ ។ លុះដល់ពេលព្រលប់ ពួកមេទ័ព នាយកង នៃកងទ័ពកុរុដែលមានជីវិតរស់នៅឡើយ បាននាំគ្នាមកគំនាប់ព្រះបរមសពក្សត្រិយ៍ម្ចាស់ជីវិតរបស់គេជាច្រើន ។

សពអ្នកចម្បាំងទាំងពួង ដែលត្រូវអាវុធស្លាប់ក្នុងទីសមរភូមិដេករដូកពាសពេញទាំងស្នាមយុទ្ធ គេបានប្រមូលយកមកទុកនៅទីមួយកន្លែងសិន នឹងលើកឡើងកាន់ជើងថ្ករាល់ ៗ សពទាំងអស់ ។ សពដែលថ្វាយព្រះភ្លើងមុនសពទាំងពួង គឺព្រះបរមសពនៃព្រះបាទទុរយោធន៍ ។ ពួកបាណ្ឌពក្សត្រិយ៍ទាំងឡាយ បានកាន់ទុក្ខថ្វាយតាមពួកកោរព ព្រោះហេតុថា ដាច់មេត្រីពីគ្នាដោយការធ្វើសង្គ្រាមក៏ពិតមែនហើយ ប៉ុន្តែអ្នកទាំងពីរខាងកើតមកអំពីពង្សនៅរួមគ្នា និងប្រតិ-



ព័ទ្ធគ្នាដោយចំណងនៃខត្តិយភាព ទើបកាន់ទុក្ខរាល់អង្គក្នុងពពួកហិណ្ឌូ ។

ធ្រឹតរាស្ត្រ វេលានេះ មុខគួរឲ្យអាណិតអាសូរជាទីបំផុត ព្រះរាជបុត្ររបស់ព្រះអង្គ ត្រូវអាវុធក្នុងសង្គ្រាមស្លាប់អស់ រាស្ត្រនិករ ក៏ស្លាប់រលស់អស់ក្រៃលពីព្រះនគរ ទ្រង់សោយទុក្ខស្លុតព្រះទ័យជាបំផុត សូម្បីព្រះនេត្រខ្វាក់ពពេមពពើមយ៉ាងនេះ ក៏នៅតែទ្រង់ខំយាងទៅឯទីយុទ្ធភូមិ ដើម្បីសម្តែងសេចក្តីអាឡោះអាល័យដល់ព្រះរាជបុត្រដែលទិវង្គតទៅទាំងនោះ ដល់ទីកន្លែងថ្វាយព្រះភ្លើង ។ ព្រះនាងខត្តិយានីទាំងឡាយក្នុងព្រះរាជសំណាក់នោះ បានស្តេចទៅឯទីថ្វាយព្រះភ្លើងសពអ្នកចម្បាំងអម្បាលនោះ[១] ។ ខត្តិយានារីទាំងអស់នាំគ្នាខ្សឹកខ្សួលបរិវេទនាការពិលាបទៅទីទៃ ៗ ។ រាជនារីទាំងឡាយមិនដែលស្តេចយាងចេញទៅខាងក្រៅវាំងទេ ប៉ុន្តែនៅគ្រានេះ ត្រូវស្តេចយាងចេញទៅដោយព្រះបាទ គ្មានសំពត់បិទបាំងព្រះភក្ត្រ ព្រះនេត្រ

១)- នៅប្រាសាទនគរវត្ត នាព្រះរបៀងទី ១ ជាន់ខាងលិចភាគខាងត្បូង គេបានឆ្លាក់រូបភាពរឿងចម្បាំងមហាភារត ត្រង់វារៈទីបំផុតនៃការសង្គ្រាម គឺគេធ្វើឲ្យឃើញរូបភាពកំពុងច្បាំងគ្នា កងទ័ពកោរពនៅខាងជើង កងទ័ពបាណ្ឌពនៅខាងត្បូង ។ ក្នុងកងទ័ពកោរពធ្វើរូបក្សត្រិយ៍ ១ អង្គ ត្រូវអាវុធទិវង្គតក្នុងសង្គ្រាម គេយកទៅតម្កល់នៅទី ១ ហើយតាំងគ្រឿងខ្ពស់សម្រាប់ក្សត្រិយ៍ ហើយធ្វើរូបក្សត្រិយ៍ប្រុសស្រីទៅប្រជុំក្នុងទីនោះជាច្រើន ។

ដែលទន់ដូចបទុមជាតិ ឥឡូវនេះក្រហាមដូចជាតិហិង្គុល និងជាំ ៗ ដោយទ្រង់ព្រះកន្សែងខ្លាំងពេក ។ អភិរូបនារីដូចទេពធីតាក្នុងកាលឥឡូវនេះ មកបម្រះនន្សៀលដោយដីប្រឡាក់ប្រឡូសអាប់អស់រាសីសក់ផ្នួងដែលតែងតែសិតសំអាងរាល់វេលា គ្រានេះ រំសាយចោលឲ្យជំពាក់ស្មុគស្មាញ និងលែងសិតស្អិតស្អាងតទៅទៀត ។ នាងក្សត្រិយានីរាប់រយជាមេម៉ាយឥតភស្ដា ដោយហេតុមហាសង្គ្រាមគ្រានេះ ។ នារីឯទៀតជាច្រើនរយអង្គបានបាត់បង់បុត្រ, បងប្អូន ឬបិតាទៅ និងអ្នកឯទៀតជាច្រើនឥតបីបើគណនា ខូចខាតអស់ទៅមួយភាគក្នុងភាគបួន មិនអាចនឹងប្រាប់បានថា អ្នកណាខូចខាតច្រើនបំផុត អ្នកណាកើតទុក្ខធ្ងន់ជាងគេបំផុត គ្រប់នារីបានសម្ដែងសេចក្ដីសោយសោកជាយ៉ាងខ្លាំង ហាក់ដូចជានាងបង់ខាតលោកិយទ្រព្យអស់រលីងធេងអំពីខ្លួន នាងជាលដំគក់ឱរា បោចពោចកេសាបម្រះនន្សៀលដោយដី ។

ព្រះបាទធ្ឫតរាស្ត្រ ទ្រង់ឈរនៅកណ្ដាលពួកនាងក្សត្រិយានីទាំងនោះ ព្រះនេត្រងងឹតឈឹងទតអ្វីឥតឃើញសោះ ទ្រង់ឈរតែស្ងៀម ៗ ឥតត្រាស់ថាអ្វីឡើយ ប៉ុន្តែក្នុងព្រះហឫទ័យពេញពោរទៅដោយទុក្ខសោកដ៏ធ្ងន់មហិមា ។ ឯការសោយសោករបស់ព្រះនាងគន្ធារីជាទេពីព្រះបាទធ្ឫតរាស្ត្រ មុខគួរឲ្យអាណោចអាធ័មយ៉ាងក្រៃលែង ព្រះនាងចូលឱបព្រះរាជបុត្រមួយអង្គម្ដង ៗ បបោសអង្អែល



ដោយសេចក្ដីស្រឡាញ់ពេញព្រះទ័យ ហើយត្រាស់សណ្ដាបចាច្រកព្រះកាណ៌ព្រះរាជបុត្រ ដែលមានវិញ្ញាណចេញទៅបាត់ហើយ ព្រះនាងធ្វើកិរិយាហាក់ដូចជាព្រះរាជបុត្ររាប់អង្គ មានព្រះជន្មនៅឡើយហាក់ដូចជាព្រះនាងយាងមកទទួលយកព្រះរាជបុត្រ ត្រឡប់ចូលក្នុងព្រះនគរវិញ ។ មុនដំបូងព្រះនាងមិនព្រមត្រាស់ចេញជាសំដីសម្ដែងទុក្ខរបស់មាតាទេ ប៉ុន្តែក្នុងទីបំផុតសេចក្ដីសោយសោកចូលគ្របសង្កត់ព្រះហឫទ័យខ្លាំងពេក ទើបព្រះនាងត្រាស់ជាបទភ្លេងពិលាបដូចតទៅនេះ ៖

«នេះ ទុរយោធន៍ ឱរសរបស់យើង ឬ ? កាលមុនដំបូង គេចេញចាកនិវេសនដ្ឋាន មានចិត្តសប្បាយរីករាយលោតកញ្ឆេងដូចអាជានេយ្យសិន្ធពជាតិ គ្មានចិត្តគិតព្រួញព្រឹក្នុងរឿងសង្គ្រាមសោះ កាលគេរៀបនឹងចេញទៅធ្វើសង្គ្រាមនោះ គេបានសុំពរពីម្ដាយថា «ព្រះមេម្ចាស់ ! សូមប្រទានពរសិរីសួស្ដីជ័យមង្គលឲ្យកូនផង» ម្ដាយបានឆ្លើយថា «កូនមាសម្ដាយ ! សុំឲ្យទេវតាពិភ័ក្តិរក្សាអ្នក ឲ្យផុតចាកភយន្តរាយទាំងឡាយ, កូនប្រុសម្ដាយ ! កុំព្រួយ ធម្មៈមាននៅក្នុងទីណា ជ័យជម្នះក៏មាននៅក្នុងទីនោះ, ឱអនិច្ចា ! នរណានឹងដឹងបានថាពាក្យដែលម្ដាយនិយាយនឹងអ្នកក្នុងគ្រានោះជាបច្ឆិមវាចា ? ប៉ុន្តែខ្លួនអ្នកមុខជាបានសោយសុខក្នុងទេវលោកហើយ ម្ដាយមិនសូវជាអាណិតអ្នកស្មើដូចព្រះរាជស្វាមីរបស់ម្ដាយទេ ព្រោះព្រះអង្គនឹង

តម្រង់ព្រះវរកាយនៅដូចម្ដេចបាន ក្នុងគ្រាដរាថមថយកម្លាំងយ៉ាងនេះ ? អើកូនម្ដាយ ! អ្នកក្លាហានណាស់ មានតេជានុភាពដ៏ខ្លាំងមហិមា រកអ្នកប្រៀបផ្ទឹមស្មើគ្មានក្នុងសង្គ្រាមជាទីស្ញប់ស្ញែងនៃអរិរាជសត្រូវរបស់អ្នក ជាក្សត្រិយ៍ដ៏ខ្ពស់ស័ក្តិ ជាបុរសអាជានេយ្យក្នុងយុគ, ឱអនិច្ចា ! ឥឡូវនេះ អ្នកចូលនិទ្រានៃអ្នកចម្បាំងក្នុងកណ្ដាលស្មាមយុទ្ធមិនបង់ជាតិកំណើតដែលកើតមកជាអង្គកូនប្រុស យកលោហិតខ្លួនលាបផែនដីជាបំណាច់ក្នុងលោក, វេលានេះអ្នកចូលទៅកាន់ស្ថានសួគ៌នៃអ្នកចម្បាំងហើយ, គ្រាដែលគេមានរាងកាយប្រឡាក់ដោយលោហិតគ្រោះគ្រាំង ដេកនៅកណ្ដាលស្មាមយុទ្ធ វិញ្ញាណរបស់គេបានឡើងទៅនិទ្រាក្នុងដួងហឫទ័យនៃព្រះអ្នកសាងមក»។

ទេពីរបស់ទុរយោធន៍ គ្រានោះព្រះនាងយាងចេញអំពីសពវីរបុរសម្នាក់ចូលទៅរកម្នាក់ទៀត នាងឱបព្រះរាជស្វាមីរបស់នាងហើយក៏ឱបលក្សណម័នជាឱរសទៀតបាក់ដូចជាមិនច្បាស់ក្នុងព្រះទ័យថា អ្នកណាមានបណ្ដាស័ក្តិខ្ពស់ជាង, អ្នកណាជាទីស្នេហាច្រើនជាងបណ្ដាអ្នកទាំងពីរនោះ, ហើយនាងទូញរៀបរាប់ថា «ទុរយោធន៍ព្រះរាជស្វាមីនៃយើងបានគ្រប់គ្រងកុរុអាណាចក្រចំនួន ១៣ ឆ្នាំនេះហើយជាក្សត្រិយ៍ជាន់ខ្ពស់ មានសក្តានុភាពយ៉ាងក្រៃលែង, ពួកបាណ្ឌពឫស្យាសេចក្ដីលំអនៃព្រះរាជអាណាចក្រ និងសេចក្ដីសុខសប្បាយសម្បូណ៌ក្នុងព្រះរាជអាណាចក្ររបស់ទ្រង់, ព្រះអង្គស៊ូទ្រាំ



ច្បាំងទាល់តែផុតដង្ហើមក្នុងទីសមរភូមិ, មើលចុះលោកអើយ ! នេះហៅថាអ្នកក្លាហាន, ឱអនិច្ចា ! កុរុអាណាចក្រអើយ តពីពេលនេះទៅគ្មានអ្នកគ្រប់គ្រងទេ ទុរយោធន៍ ព្រះរាជស្វាមីរបស់យើង ព្រះអង្គបានលះបង់សិរីរាជ្យសម្បត្តិ ក្នុងលោកកណ្ដាលនេះ នៅផ្ទំក្នុងមន្ទីរស្ថានលោកដទៃ, ឯលោកដទៃគឺស្ថានសួគ៌ជាន់ខ្ពស់ជាប្រាកដ បើគម្ពីរវេទពោលនោះពិតមែន, បើទេព្ដាមិនចេះនិយាយមុសាវាទទេ»។

ពិធីឈាបនកិច្ចអស់ពេលវេលាជាយ៉ាងយូរ មិនមែនព្រោះតែសពច្រើនប៉ុណ្ណោះទេ ព្រោះតែកុលស្ត្រីទាំងនោះចេះតែបរិវេទនាការមិនចេះអស់មិនចេះហើយ គេមិនអាចនឹងបេះយកសពចេញពីទ្រូងនៃស្ត្រីអ្នកយំសោកទាំងនោះបាន ក្នុងទីបំផុត សពទាំងអស់ត្រូវគេលើកយកទៅបូជានៅវេលាអ្នកទាំងនោះកំពុងតែក្ដុកក្ដួលក្នុងឱរា ។ លុះស្រេចការបូជាសពហើយ បណ្ដាអ្នកមានទុក្ខទាំងអស់ក៏នាំគ្នាដើរទៅឯឆ្នេរព្រះគង្គាដើម្បីនឹងជម្រះកាយក្នុងទឹកដ៏ស័ក្តិសិទ្ធិ និងដើម្បីឧទ្ទិសមតកភត្តទៅឲ្យវិញ្ញាណអ្នកស្លាប់ហើយ ។ នៅវេលាដែលគេកំពុងតែធ្វើបុណ្យនោះ ព្រះនាងប្រិថាយ៉ាងចូលទៅរកឱរសទាំង ៥ អង្គ គឺពួកបាណ្ឌពបញ្ចេញសេចក្ដីសម្ងាត់ រឿងសម្ភពជាតិរបស់មេទ័ពកណ៌ ដែលជាសឹកសត្រូវនឹងអរជុនយ៉ាងសំខាន់នោះឥឡូវនេះត្រឡប់ក្លាយទៅជាបងប្អូនរបស់គេវិញ កណ៌ទើបតែបានដឹងរឿងរបស់ខ្លួនអំពីភីស្មៈ ក្នុងវេលាដែលជិតនឹងស្លាប់ហើយ ប៉ុន្តែ

គ្មានអ្នកណាដឹងទៀត ទាល់តែនាងប្រិថា មានសេចក្តីសង្វេគស្លុតចិត្តមកបញ្ចេញប្រាប់ក្នុងវេលានេះ ហើយនាងសុំឲ្យឧទ្ទិសចំណែកកុសលទៅឲ្យកណ៌ដែលត្រូវជាបងច្បងនោះផង ។

ស្រេចការឈាបនកិច្ចហើយ គណៈរដ្ឋមន្ត្រីប្រកាសការរាជាភិសេកយុធិស្ឋិរជាព្រះមហារាជានៃអាណាចក្រហស្តិនបុរ រួមទាំងអាណាចក្រឥន្ទ្របថមកផងដូចអំពីដើម ប៉ុន្តែទ្រង់គ្មានត្រេកត្រអាលឬឡឹតយសស័ក្តិយ៉ាងណាមួយ ដើម្បីយកមកជារង្វាន់ជំនួសសេចក្តីលំបាកតោកយ៉ាកដែលទ្រង់បានត្រាំត្រែងរងវេទនាជាយូរ នៅវេលាត្រូវគេនិរទេសនោះ ឬជំនួសការខូចខាតដែលទ្រង់បានខូចបង់ទៅក្នុងវេលាធ្វើសង្គ្រាមនោះសោះឡើយ, ព្រះហឫទ័យរបស់ទ្រង់ចេះតែក្រំក្រៀមពេញទៅដោយទុក្ខទោមនស្ស ។ សម្បត្តិសម្បូណ៌ពោរពាសនឹងការសម្តែងចិត្តភក្តីទាំងនេះ មិនមែនធ្វើឲ្យព្រះមហារាជយុធិស្ឋិរមានព្រះហឫទ័យត្រេកត្រអាលសោមនស្សទេមានតែបន្ថែមទុក្ខឲ្យរីងរឹតតែខ្លាំងធ្ងន់ឡើងប៉ុណ្ណោះ ។ រាល់ទិវារាត្រីទ្រង់មានព្រះហឫទ័យក្តុកក្តួលរំជួលគិតដល់រឿងកាប់សម្លាប់ញាតិសន្តានបងប្អូនដ៏ជាអំពើបាបកម្ម ។ ក្នុងទីបំផុត លោកឫសីវយាសៈចូលទៅគាល់ហើយទូលពន្យល់ទ្រង់ឲ្យធ្វើអស្វមេធយញ្ញគឺពិធីសម្លាប់សេះបូជាយិជដែលគេពោលថាអាចនឹងលុបលាងបាបកម្មរបស់ព្រះអង្គបាន។

គណៈរដ្ឋមន្ត្រីបានចេញប្រកាស ឲ្យស្រាវជ្រាវរកសេះសន្ទូន



សម្បុរដូចពន្លឺព្រះចន្ទ្រមានត្រចៀកខ្មៅម្ខាង ។ លុះគេរកបានសេះដូចថានេះមកហើយ ចារិកព្រះនាមថា «យុធិស្ឋិរ» នៅផែនមាសនោះស្រេចហើយ យកផែនមាសទៅចងភ្ជាប់នឹងមុខសេះនោះ រួចលែងសេះនោះឲ្យវាដើរទៅតាមចិត្តវា មានកងទ័ពមួយកងនៅក្នុងបង្គាប់បញ្ជាអរជុនលើកតាមទៅពិនិត្យមើលការណ៍ផង ។

ការសម្លាប់សេះបូជាយិជនោះ ជាការប្រកាសផ្សាយឥស្សរភាពឲ្យពួកផងទាំងពួងដឹងឮថា ជាស្តេចធំលើរដ្ឋសីមាទាំងឡាយដែលនៅជិតខាងជុំវិញតាមប្រពៃណីជាប់ត ៗ មកយ៉ាងនេះ «បើក្សត្រិយ៍អង្គណាមួយក្នុងប្រទេសជិតខាង អាចហ៊ានចាប់សេះនោះឃុំខាំងទុកក៏ឲ្យជាទីសំគាល់បានថា ជាអាណត្តិសញ្ញានឹងប្រកាសសង្គ្រាមតទល់វិញ, ក្សត្រិយ៍ដែលចាប់សេះទុកនោះ ត្រូវលើកទ័ពមកច្បាំងនឹងកងទ័ពដែលលើកតាមសេះទៅនោះ បើក្សត្រិយ៍អ្នកម្ចាស់នគរនោះចាញ់ ត្រូវប្រគល់កងទ័ពរបស់ខ្លួន ឲ្យដល់កងទ័ពសេះបន្ថែមកម្លាំងទ័ពឲ្យច្រើនឡើងទៀត ហើយលើកតទៅមុខទៀត, បើគ្មានក្សត្រិយ៍អង្គណាមួយអាចហ៊ានចាប់សេះនោះទុកទេ បណ្តោយឲ្យសេះដើរជាន់ព្រះនគរតាមចិត្តហើយ ក៏ទុកជាគ្រឿងសំគាល់ថាក្សតិយ៍ជិតខាងគ្រប់នគរខ្លបខ្លាចព្រះចេស្តាហើយ ពេញចិត្តនឹងទទួលគោរពរាប់អានក្សត្រិយ៍ម្ចាស់សេះនោះថា ជាចៅហ្វាយនាយធំបំផុតរបស់ខ្លួន, លុះដល់សេះនោះត្រាច់ទៅសុសសព្វព្រះនគរជិត